មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចេញផ្សាយកំណត់ត្រាសង្ខេបស្តីពី
# ធុរកិច្ចនិងសិទ្ធិមនុស្ស៖ គណនេយ្យភាពសាជីវកម្មចំពោះការរំលោភបំពានលើសិទ្ធិដីធ្លី

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ចេញផ្សាយកំណត់ត្រាសង្ខេបស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សដែលមានចំណងជើងថា **គណនេយ្យភាពសាជីវកម្មចំពោះការរំលោភសិទ្ធិបំពានលើសិទ្ធិដីធ្លី**។ កំណត់ត្រាសង្ខេបនេះមានគោលបំណងបង្ហាញនូវទិដ្ឋភាពទូទៅអំពីការប្រឈម ដើម្បីស្វែងរកគណនេយ្យភាពរបស់ក្រុមហ៊ុនសាជីវកម្មនៅក្នុងប្រទេសកម្ពុជា ដោយពិនិត្យទៅលើយន្តការដែលមានស្រាប់ផ្សេងៗគ្នា សម្រាប់អ្នកដែលប្រឈមនឹងការរំលោភបំពានលើសិទ្ធិដីធ្លីនៅក្នុងប្រទេស និងវិធីសាស្ត្រមួយចំនួនដែលសហគមន៍បានប្រើប្រាស់ដើម្បីទទួលបានដំណោះស្រាយ។ កំណត់ត្រាសង្ខេបនេះអាចស្វែងរកបានតាមរយៈតំណភ្ជាប់ភាសាខ្មែរ និង ភាសាអង់គ្លេស។ លោកអ្នកក៏អាចស្វែងរកបានផងដែរនូវកំណត់ត្រាសង្ខេបមុនៗរបស់ ម.ស.ម.ក ដោយការទាញយកនៅទីនេះជាភាសាខ្មែរ និងភាសាអង់គ្លេស។

ការរំលោភបំពានលើសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាសិទ្ធិមនុស្សនានាដែលកើតឡើងជាញឹកញាប់ក្នុងយុគសម័យទំនើបនៃប្រទេសកម្ពុជាបច្ចុប្បន្ន។ ផ្នែកមួយដ៏សំខាន់នៃបញ្ហានេះ គឺជាការលំបាកក្នុងការបញ្ចុះបញ្ចូលក្រុមហ៊ុននានាឱ្យធានាបាននូវគណនេយ្យភាពចំពោះផលប៉ះពាល់លើសិទ្ធិមនុស្សរបស់ខ្លួន។ ធុរកិច្ចនៅទូទាំងសកលលោកគឺមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលចំពោះសិទ្ធិមនុស្សស្ទើរតែទាំងអស់របស់មនុស្ស។ ជាក់ស្តែង នៅក្នុងបញ្ហាទំនាស់ដីធ្លី ក្រុមហ៊ុនតែងត្រូវបានចោទប្រកាន់អំពីការរឹបអូសយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការមិនគោរពសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ តាមទ្រឹស្តី សហគមន៍របស់ប្រទេសកម្ពុជាអាចស្វែងរកដំណោះស្រាយទៅលើការរំលោភបំពានលើសិទ្ធិដីធ្លីតាមរយៈវិធីសាស្ត្រជាច្រើនរួមមាន តាមរយៈក្រុមហ៊ុន អង្គភាពរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ និងតុលាការ ប៉ុន្តែការអនុវត្តជាក់ស្តែង ការស្វែងរកគណនេយ្យភាពរបស់ក្រុមហ៊ុនសាជីវកម្មគឺជារឿងមួយដ៏លំបាក។

នៅក្នុងកំណត់ត្រាសង្ខេបនេះ ម.ស.ម.ក ពិនិត្យមើលទៅលើបញ្ហាប្រឈមនានាក្នុងការស្វែងរកគណនេយ្យភាពរបស់ក្រុមហ៊ុនសាជីវកម្មសម្រាប់សហគមន៍នៅក្នុងករណីទំនាស់ដីធ្លីចំនួនបួន ដែលករណីទាំងនេះបានប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន១៨០០ គ្រួសារ ៖ ទំនាស់ដីធ្លីជាប់ពាក់ព័ន្ធជាមួយសហគមន៍ជនជាតិដើមភាគតិច និងក្រុមហ៊ុនចំការកៅស៊ូ សុកហ៊្វីន ខេ.ស៊ី.ឌី នៅខេត្តមណ្ឌលគិរី ទំនាស់ដីធ្លីពាក់ព័ន្ធជាមួយអ្នកភូមិ

និងក្រុមហ៊ុនស្ករមីតផលកូល នៅខេត្តឧត្តរមានជ័យ ទំនាស់ដីធ្លីពាក់ព័ន្ធនឹងអ្នកភូមិជាមួយក្រុមហ៊ុន អឹម.ឌី.អេស នៅតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា នៅក្នុងខេត្តពោធិ៍សាត់ និងចុងក្រោយគឺទំនាស់ដីធ្លីរវាងអ្នកភូមិនិងក្រុមហ៊ុនឧស្សាហកម្មស្ករកោះកុង ខូ អែល ធី ឌី និងក្រុមហ៊ុនចម្ការកោះកុង ខូ អែល ធី ឌី នៅខេត្តកោះកុង។

ជាលទ្ធផលនៃការស្រាវជ្រាវ ម.ស.ម.ក រកឃើញនូវបញ្ហាគួរឲ្យព្រួយបារម្ភចំនួនប្រាំបួន ដែលរារាំងនូវការសម្រេចបាននូវគណនេយ្យភាពរបស់ក្រុមហ៊ុនសាជីវកម្មនៅកម្ពុជា។ កំណត់ត្រាសង្ខេបនេះលើកឡើងនូវអនុសាសន៍ចំនួន ២៦ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុននានាដែលកំពុងប្រតិបត្តិការនៅកម្ពុជា និងអង្គការសង្គមស៊ីវិលក្នុងការទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយចំពោះការបារម្ភទាំងនេះ ដោយប្រសិទ្ធិភាពដើម្បីលើកកម្ពស់យុត្តិធម៌ តម្លាភាពនិងដំណើរការដោះស្រាយទំនាស់ដីធ្លីនៅទូទាំងប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានលម្អិតសូមមើលមូលន័យសង្ខេបនៃកំណត់ត្រាសង្ខេបដែលបានភ្ជាប់ក្នុងឯកសារនេះ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់ ម.ស.ម.ក តាមរយៈលេខទូរស័ព្ទ (+៨៥៥) (០) ១២ ៩៤១ ២០៦ ឬតាមរយៈអ៊ីម៉ែល** vann.sophath@cchrcambodia.org។

**– ចប់ –**

<u>**បណ្ណាធិការ៖**</u>

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា «ម.ស.ម.ក» បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃអង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ ("IFEX") ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម ("OMCT") ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អេស.អូ.អេស និងសម្ព័ន្ធ Civicus និងជាសមាជិក OECD-Watch ផងដែរ។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងទទួលបានពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គមនៅសកលវិទ្យាល័យឃ្វីនស្លែនក្នុងទីក្រុងប្រីសប៊ែន (Briesbane) ប្រទេសអូស្ត្រាលី។